**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ១៣-០១៦-៨៤៣-ស.ជ.ព

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា LPCO

កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ ធនាគារជាតិនៃកម្ពុជាបានអនុវត្តប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ជាលើកទី១ ប្រកបដោយជោគជ័យ ដោយបានផ្តល់សន្ទនីយភាពជាប្រាក់រៀលដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុដែលមានគុណវុឌ្ឍិគ្រប់គ្រាន់សម្រាប់ឥណប្រតិទាន ៣ខែ ជាមួយនឹងការដាក់មូលបត្រអាចជួញដូរបានជាវត្ថុធានា ។ ដោយពិនិត្យឃើញសក្តានុពលនៃតម្រូវការសន្ទនីយភាពជាប្រាក់រៀលរបស់បណ្តាគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុនៅក្នុងប្រតិបត្តិការទី១ និងទទួលបានទស្សនៈឆ្លើយតបជាវិជ្ជមានចំពោះការបន្តអនុវត្តប្រតិបត្តិការ LPCO ថែមទៀត ធនាគារជាតិនៃកម្ពុជាសម្រេចដូចខាងក្រោម ៖

- បន្តអនុវត្តប្រតិបត្តិការ LPCO ជារៀងរាល់ខែ ក្នុងរយៈពេល៦ខែ យោងតាមប្រតិទិនដូចភ្ជាប់មកជាមួយ ។
- ប្រតិបត្តិការ LPCO លើកទី២នឹងត្រូវដំណើរការអនុវត្តនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦ ។
- ប្រតិបត្តិការ LPCO នឹងបន្តអនុវត្តផ្អែកលើយន្តការអត្រាតែមួយ (Dutch Auction) ។
- អត្រាការប្រាក់ដេញថ្លៃអប្បបរមា នឹងប្រកាសជូននៅកាលបរិច្ឆេទនៃការដេញថ្លៃនីមួយៗ ។
- ទំហំទឹកប្រាក់នៃការដេញថ្លៃសម្រាប់ប្រតិបត្តិការ LPCO នឹងប្រកាសជូនមួយសប្តាហ៍មុនកាលបរិច្ឆេទនៃការដេញថ្លៃនីមួយៗ ។
- គ្រឹះស្ថានដែលទទួលជោគជ័យ ត្រូវត្រៀមបម្រុងមូលបត្រអាចជួញដូរបាន (NCD) ឬមានទឹកប្រាក់ក្នុងគណនីចរន្តគ្រប់គ្រាន់ ដើម្បីធានាលើប្រតិបត្តិការ LPCO និង
- ធនាគារជាតិនៃកម្ពុជា នឹងវិភាគយ៉ាងប្រុងប្រយ័ត្នលើលទ្ធផលនិងផលប៉ះពាល់នៃប្រតិបត្តិការ LPCO នីមួយៗ និងរក្សាសិទ្ធិកែប្រែលក្ខខ័ណ្ឌនៃប្រតិបត្តិការ LPCO នាពេលអនាគតប្រសិនបើចាំបាច់ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបជាព័ត៌មាន ។

សូមទំនាក់ទំនង៖
ធនាគារជាតិនៃកម្ពុជា
អគ្គនាយកដ្ឋានបច្ចេកទេស
នាយកដ្ឋានប្រតិបត្តិការ
សារអេឡិចត្រូនិក៖ lpco_info@nbc.org.kh